Organized by

Supported by

# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

## Inside

### Infographic
"Cambodia-Republic of Korea Trade Statistics and Facts"

### Policy Recommendation
Summary of Recommendations
*"Strengthening the Multilateral Trading System to Promote Inclusivity and Development: A Webinar Series"*



វ៉ុល០៣ | លេខ០៣ | ខែមីនា ឆ្នាំ២០២៣
VOLUME 03 | ISSUE 03 | MARCH 2023

ព្រឹត្តិបត្រពាណិជ្ជកម្ម

# ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម កម្ពុជា និងសាធារណរដ្ឋកូរ៉េ

រៀបចំដោយ

គាំទ្រដោយ

## ច្រកទីផ្សារកូរ៉េ

កម្ពុជាទទួលបាន **អត្រាពន្ធអនុគ្រោះសម្រាប់ការនាំចេញ** ទៅកាន់កូរ៉េ ក្រោមក្របខ័ណ្ឌដូចខាងក្រោម:

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា និងកូរ៉េ (CKFTA)
*ចូលជាធរមាននៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២*

កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)
*ចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២*

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន និងកូរ៉េ (AKFTA)
*ចូលជាធរមាននៅខែមិថុនា ឆ្នាំ២០០៧*

ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មផ្តល់ក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក

## ពាណិជ្ជកម្មនិងវិនិយោគទ្វេភាគី

**១៤**

ដៃគូពាណិជ្ជកម្មធំជាងគេលំដាប់ទី១៤ របស់កម្ពុជា

កូរ៉េបានក្លាយជា **ដៃគូពាណិជ្ជកម្មធំជាងគេលេខរៀងទី១៤** របស់កម្ពុជា នៅក្នុងឆ្នាំ២០២២

**៧៧៤ លានដុល្លារ** ២០២១

**៧៧៩ លានដុល្លារ** ២០២២ (+០,៦%)

### ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-កូរ៉េ




កម្ពុជា**នាំចេញទៅ**កូរ៉េ

| | |
|---|---|
| ១៩៤ លានដុល្លារ | ២០២១ |
| ២៣៤ លានដុល្លារ | ២០២២ (+២០,៤%) |

កម្ពុជានាំចូលពីកូរ៉េ

| | |
|---|---|
| ៥៨០ លានដុល្លារ | ២០២១ |
| ៥៤៥ លានដុល្លារ | ២០២២ (-៦%) |

ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## កំណើនការនាំចេញបានពីកិច្ចព្រមព្រៀង CKFTA

ការគណនាលើឥទ្ធពលនៃកិច្ចព្រមព្រៀង CKFTA លើកំណើនផលិតផលក្នុងស្រុកសរុប ដោយសារបម្រែបម្រួលនៃការនាំចេញរបស់កម្ពុជា

| | |
|---|---|
| ការនាំចេញរបស់កម្ពុជា (ផលិតកម្ម & សេវាកម្ម) ▲+៣% | ការនាំចេញរបស់កម្ពុជា (ផលិតកម្ម & សេវាកម្ម) ▲+៤% ** |
| កំណើនផលិតផលក្នុងស្រុកសរុប: ▲+០,៦៣% | កំណើនផលិតផលក្នុងស្រុកសរុប: ▲+០,៨៥% ** |

ប្រភព៖ ERIA (2023), Structural Transformation and the Global Production Value Chain: Potential Impact of the CKFTA on Cambodia

** កម្រិតកាន់តែខ្ពស់ឆ្លុះបញ្ចាំងពីសេរីភាវូបនីយកម្មពេញលេញនៃសេដ្ឋកិច្ចកម្ពុជា ដែលរួមមានលំហូរនៃជំនាញ បញ្ហាមិនមែនព្រំដែន ការសម្របសម្រួលពាណិជ្ជកម្ម និងវិនិយោគ និងការកែទម្រង់ស្ថាប័ន និងទីផ្សារការងារ

### វិនិយោគផ្ទាល់របស់កូរ៉េនៅកម្ពុជា

កូរ៉េជាប់ **លេខរៀងទី៣ មានវិនិយោគទុនច្រើនជាងគេ** នៅកម្ពុជា ឆ្នាំ២០២១

**២៨៣,៥ លានដុល្លារ** (៨,១%)

កម្ពុជាទទួលបានការវិនិយោគផ្ទាល់ពីបរទេសសរុប ប្រមាណ ៣,៥ ប៊ីលានដុល្លារក្នុងឆ្នាំ២០២១

ប្រភព៖ Financial Stability Review 2021 of National Bank of Cambodia

## ក្រុមទំនិញនាំចេញ និងនាំចូលសំខាន់ៗ

● ការនាំចេញរបស់កម្ពុជា ទៅកូរ៉េ

● ការនាំចូលរបស់កម្ពុជា ពីកូរ៉េ

ការនាំចេញរបស់កម្ពុជា ទៅកូរ៉េ:

- ស្បែកជើង ស្រោមជើង និងវត្ថុប្រហាក់ប្រហែល — ៥៤ លានដុល្លារ
- សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំធ្វើឡើងពីក្រណាត់ចាក់ — ៥២ លានដុល្លារ
- ម៉ាស៊ីន និងឧបករណ៍អគ្គិសនី និងបំណែកភាគរបស់វា — ៤៥ លានដុល្លារ
- សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់មិនធ្វើឡើងពីការចាក់ — ៣៥ លានដុល្លារ
- អាលុយមីញ៉ូម និងវត្ថុធ្វើពីអាលុយមីញ៉ូម — ១២ លានដុល្លារ



ការនាំចូលរបស់កម្ពុជា ពីកូរ៉េ:

- យាន ក្រៅពីអយស្ម័យយាន ឬអយរថអគ្គិសនី និងបំណែកភាគ — ១៣២ លានដុល្លារ
- ភេសជ្ជៈ ស្រា និងទឹកខ្មេះ — ៥២ លានដុល្លារ
- ស្បែកផៅ (ក្រៅពីស្បែកជាប់រោម) និងស្បែកសម្លាប់ — ៥៥ លានដុល្លារ
- ម៉ាស៊ីន និងឧបករណ៍អគ្គិសនី និងបំណែកភាគរបស់វា — ៣១ លានដុល្លារ
- ផលិតផលបានពីការចាក់ដោយម្ជុល — ៣៤ លានដុល្លារ

ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

iTrade Bulletin

Organized by

Supported by

# CAMBODIA-REPUBLIC OF KOREA TRADE STATISTICS AND FACTS

## Korea Market Access

Cambodia got **preferential tariff treatment on exports** to Korea via the following frameworks:

- Cambodia-Korea Free Trade Agreement (CKFTA)
  *entered into force on 01 Dec 2022*
- Regional Comprehensive Economic Partnership (RCEP)
  *entered into force on 01 Jan 2022*
- ASEAN-Korea Free Trade Agreement (AKFTA)
  *entered into force on June 2007*
- The Generalized System of Preferences under the WTO framework

## Bilateral Trade & FDI

**14TH** Largest Trading Partner with Cambodia

**Korea** has became Cambodia's 14th largest trading partner in 2022.

| Year | Trade |
| --- | --- |
| 2021 | $ 774 million |
| 2022 | $ 779 million *(+0.6%)* |

## Cambodia-Korea Import and Export




Cambodia **exported to** Korea

| Year | Value |
| --- | --- |
| 2021 | $ 194 million |
| 2022 | $ 234 million *(+20.4%)* |

Cambodia **imported from** Korea

| Year | Value |
| --- | --- |
| 2021 | $ 580 million |
| 2022 | $ 545 million *(-6%)* |

Source: General Department of Customs and Excise

## CKFTA'S IMPACTS OF EXPORT CHANGES

Simulation of the impacts of export changes to Cambodia's GDP via CKFTA

| Cambodia's Export: (manufacturing & services) | Cambodia's GDP Growth: |
| --- | --- |
| ▲+3% | ▲+0.63% |
| ▲+4% ** | ▲+0.85% ** |

Source: ERIA (2023), Structural Transformation and the Global Production Value Chain: Potential Impact of the CKFTA on Cambodia

** The higher threshold reflects full liberalization of the Cambodian economy, including movement of skills, behind-the-border issue, trade and investment facilitation, and institutional and labour market reforms.

## Korea's FDI in Cambodia

In 2021, Korea was the 3rd largest investor in Cambodia.

**283.5 USD million** *(8.1%)*

Cambodia received foreign direct investment about $3.5 billion in 2021.

Source: Financial Stability Review 2021 of National Bank of Cambodia

## Top Imported and Exported Product Groups

- Cambodia's Export to Korea
- Cambodia's Import from Korea

**Cambodia's Export to Korea**

- Footwear, gaiters and the like — $ 54 million
- Articles of apparel and clothing accessories, knitted or crocheted — $ 52 million
- Electrical machinery and equipment and parts thereof — $ 45 million
- Articles of apparel and clothing accessories, not knitted or crocheted — $ 35 million
- Aluminium and articles thereof — $ 12 million



**Cambodia's Import from Korea**

- Vehicles other than railway or tramway rolling-stock, and parts — $ 132 million
- Beverages, spirits and vinegar — $ 52 million
- Raw hides and skins (other than furskins) and leather — $ 55 million
- Electrical machinery and equipment and parts thereof — $ 31 million
- Knitted or crocheted fabrics — $ 34 million

Source: General Department of Customs and Excise

## កម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម បានប្រកាសបញ្ចប់ជាផ្លូវការនូវការចរចាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម

ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និងឯកឧត្តមបណ្ឌិត ថានី ប៊ីន អាម៉េត អាល់ ហ្សេយូឌី រដ្ឋមន្ត្រីទទួលបន្ទុកពាណិជ្ជកម្មអន្តរជាតិនៃក្រសួងសេដ្ឋកិច្ចអេមីរ៉ាតអារ៉ាប់រួម បានប្រកាសរួមគ្នា អំពីការបញ្ចប់ការចរចាផ្លូវការនៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ កម្ពុជា-អេមីរ៉ាតអារ៉ាប់រួម តាមរយៈប្រព័ន្ធវីដេអូ។ សេចក្តីប្រកាសនេះបានធ្វើឡើង បន្ទាប់ពីមានកិច្ចប្រជុំផ្លូវការចំនួន ៣ ជុំ រួចមក ដោយមានវត្តមានចូលរួមអ្នកចូលរួមប្រមាណ ១០០នាក់ រួមទាំងសមាជិកនៃប្រធានក្រុមចរចា តំណាងក្រសួង ស្ថាប័នជាច្រើនពីប្រទេសទាំងពីរ។ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយគឺជាប្រភេទនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយ ដែលជាទូទៅត្រូវបានរចនាឡើងសម្រាប់ការគ្របដណ្តប់យ៉ាងទូលំទូលាយលើសពីទំនិញ និងបានចែងអំពីបទបញ្ញត្តិសម្រាប់សេវាកម្ម ការវិនិយោគ ការដោះស្រាយវិវាទ កម្មសិទ្ធិបញ្ញា លទ្ធកម្មរដ្ឋាភិបាល និងទម្រង់បន្ថែមនៃសេដ្ឋកិច្ចឯកទេស។ *ប្រភព ៖ Phnom Penh Post*

## រោងចក្រផលិតកង់ឡាននៅខេត្តព្រះសីហនុ បង្កើនក្តីសង្ឃឹមសម្រាប់ដំណាំកៅស៊ូ

រោងចក្រផលិតកង់ឡានដ៏ធំនិងទើបតែដំណើរការមួយ ដែលមានទុនវិនិយោគ ៣០០លានដុល្លារ អាម៉េរិក ដោយក្រុមហ៊ុនចិន General Tires Technology គឺជាការវិវឌ្ឍថ្មីមួយ ដែលក្រុមហ៊ុនក្នុងស្រុកលើវិស័យដំណាំកៅស៊ូនិងរថយន្តកំពុងទន្ទឹងរង់ចាំ និងអាចដើរតួនាទីយ៉ាងសំខាន់ដើម្បីរក្សាស្ថិរភាពតម្លៃកៅស៊ូពីផលប៉ះពាល់ដោយសារទីផ្សារអន្តរជាតិ។ រោងចក្រនេះបានបើកដំណើរកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ ដែលមានទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ លើផ្ទៃដីទំហំ ១៨ហិកតា។ លោក គូ គុយ ប្រធានក្រុមហ៊ុន General Tires Technology បានឱ្យដឹងថា ក្នុងមួយឆ្នាំរោងចក្រអាចមានលទ្ធភាពផលិតកង់ឡានខ្នាតតូចបានចំនួន ៥លានកង់ និងខ្នាតធំចំនួន ៩សែនកង់ ដែលភាគច្រើនសម្រាប់នាំចេញទៅទីផ្សារអាម៉េរិក អឺរ៉ុប និងប្រេស៊ីល។ *ប្រភព ៖ Phnom Penh Post*

## ការនាំចេញដំឡូងមីនឹងកើនឡើងតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងគោលនយោបាយជាតិ

ឯកឧត្តម រាជ រ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានឱ្យដឹងថាបច្ចុប្បន្នកម្ពុជានាំចេញដំឡូងមីជាមធ្យម ២៩៣.៦៥៣តោន ក្នុងមួយខែ ចន្លោះពីខែមករាដល់ខែវិច្ឆិកា ឆ្នាំ២០២២ ដែលចំនួននេះនឹងកើនឡើងបន្ថែមទៀត ដោយសារតែមានកំណើនការបញ្ជាទិញក្នុងតំបន់ និងការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីប្រកបដោយប្រសិទ្ធភាពនិងទូលំទូលាយ ព្រមទាំងការគាំទ្រពីគោលនយោបាយថ្នាក់ជាតិស្តីពីដំឡូងមី។ ឯកឧត្តមក៏បានលើកឡើងបន្ថែមទៀតថា ក្រសួងពាណិជ្ជកម្ម កំពុងធ្វើការយ៉ាងជិតស្និទជាមួយក្រសួងស្ថាប័នរដ្ឋ និងវិស័យឯកជនដទៃទៀតក្នុងការដឹកនាំការចរចា ដើម្បីសម្រេចនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបីទៀត ដែលនឹងក្លាយជាចលករសំខាន់មួយជំរុញការនាំចេញដំឡូងមីកម្ពុជា ទៅកាន់ទីផ្សារប្រទេសហត្ថលេខីនិងវិស័យពាក់ព័ន្ធផ្សេងទៀត ក៏ដូចជាជំរុញលទ្ធភាពទីផ្សារសម្រាប់អ្នកវិនិយោគ។ យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កម្ពុជាបាននាំចេញផលិតផលដំឡូងមីចំនួន ៣,២៣លានតោន គិតពីខែមករាដល់វិច្ឆិកា ឆ្នាំ២០២២ ក្នុងនោះរួមមានចំណិតដំឡូងមីស្ងួតចំនួន ១,៨១៧លានតោន ដំឡូងមីស្រស់ ១,៣៣២លានតោន ម្សៅដំឡូងមីចំនួន ៥៧.០៦៧តោន និងកាកសំណល់ដំឡូងមីចំនួន ២៤.១០០តោន។ យោងតាមរបាយការណ៍នេះ ប្រទេសដែលទិញផលិតផលដំឡូងមីកម្ពុជាមានថៃ វៀតណាម ចិន អាម៉េរិក អ៊ីតាលី ហូឡង់ កាណាដា ម៉ាឡេស៊ី ឥណ្ឌា និងសិង្ហបុរី។ *ប្រភព ៖ Phnom Penh Post*

## កម្ពុជាថា ពាណិជ្ជកម្មសេវាមានសារសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច

ឯកឧត្តម ស៊ីម សុខខេង រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មបានមានប្រសាសន៍ថា ពាណិជ្ជកម្មសេវាមានសារសំខាន់ដូចពាណិជ្ជកម្មទំនិញសម្រាប់កំណើនសេដ្ឋកិច្ច។ ក្នុងពេលជាអធិបតីក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពី “ការចរចាពាណិជ្ជកម្មសេវាកម្មក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO)៖ ផ្នែកសំខាន់ៗនិងវឌ្ឍនភាពថ្មីៗ” ឯកឧត្តម បានលើកឡើងថា ពាណិជ្ជកម្មសេវាកម្មគឺមានសារៈសំខាន់ដូចគ្នានឹងពាណិជ្ជកម្មទំនិញដែរ នៅពេលនិយាយអំពីកំណើនសេដ្ឋកិច្ច។ យោងតាមទិន្នន័យអាស៊ាន វិស័យសេវាកម្មបានរួមចំណែក ក្នុងផលិតផលក្នុងស្រុកសរុបរបស់ប្រទេសសមាជិកអាស៊ានចន្លោះពី ៣៨% ទៅ ៦៩%។ ពាណិជ្ជកម្មសេវារបស់ប្រទេសកម្ពុជាបានរួមចំណែកច្រើនជាង ៤០% នៃសេដ្ឋកិច្ចជាតិ។ ឯកឧត្តមបានបង្ហាញថា តាមរយៈសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវា កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម នៅពេលចូលជាសមាជិកអាស៊ានក្នុងឆ្នាំ១៩៩៩។ បន្ទាប់ពីចូលជាសមាជិកពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤ កម្ពុជាបានធ្វើសេរីភាវូបនីយកម្មអនុវិស័យចំនួន ៩៤ លើវិស័យសំខាន់ៗចំនួន ១១ ដូចជា ( ១)សេវាអាជីវកម្ម (២)សេវាទំនាក់ទំនង (៣)សេវាកម្មសំណង់និងវិស្វកម្មពាក់ព័ន្ធ (៤)សេវាចែកចាយ (៥)សេវាអប់រំ (៦)សេវាបរិស្ថាន (៧)សេវាហិរញ្ញវត្ថុ (៨)សេវាសុខភាពនិងសង្គម (៩)សេវាកម្មទាក់ទងនឹងទេសចរណ៍និងការធ្វើដំណើរ (១០)សេវាកម្សាន្ត វប្បធម៌ និងកីឡា និង (១១)សេវាកម្មដឹកជញ្ជូន។ *ប្រភព ៖ Khmer Times*

### Cambodia, UAE Conclude Talks on Trade Pact

Commerce minister Pan Sorasak and other officials at a ceremony for the joint announcement of the formal conclusion of talks for the CAM-UAE CEPA on March 16. MOC Minister of Commerce Pan Sorasak and Emirati Minister of State for Foreign Trade Thani bin Ahmed al-Zeyoudi on March 16 jointly announced the formal conclusion of talks for the Cambodia-United Arab Emirates Comprehensive Economic Partnership Agreement (CAM-UAE CEPA) via video link. The announcement comes after three rounds of formal negotiations, and was made in the presence of around 100 people, including the members and chairpersons of the negotiating teams, as well as representatives of several ministries and institutions from both countries, according to a commerce ministry statement. A CEPA is a type of free trade agreement (FTA) that is generally designed for a more holistic coverage beyond just commodities, and can contain provisions for services, investments, dispute resolution, intellectual property rights, government procurement, and additional forms of specialised economic cooperation. *Source: Phnom Penh Post*

### Preah Sihanouk Tyre Plant Lifts Hopes for Rubber

A massive, freshly-launched tyre factory, backed by a $300 million investment from Chinese-owned General Tires Technology (Cambodia) Co Ltd, could be the breakthrough that the local rubber and automotive sectors have been waiting for, and potentially act as a type of price stabiliser for domestic natural latex that blunts the adverse effects of fluctuations from international markets. An official ceremony was held on March 18, marking the launch of the plant, located on an 18ha site in Preah Sihanouk province's Sihanoukville Special Economic Zone (SSEZ). At the event, General Tires Technology chairman Gu Cui disclosed that the facility will have an annual production capacity of five million "small" tyres and 900,000 "large" ones – which he said are mainly to be exported. Target markets include the US, Europe and Brazil, he revealed. *Source: Phnom Penh Post*

### Cassava Exports to Rise on FTA Use, Policy

Cambodian cassava exports are about to pick up steam and soar beyond the 293,653-tonne monthly average over January-November 2022, propelled by a growing pool of regional buyers and increasingly comprehensive and effective exploitation of free trade agreements (FTA), as well as a national policy on the South American-native root vegetable, according to Ministry of Commerce secretary of state Reach Ra on March 14. Ra recapped that the commerce ministry – working closely with other government agencies, institutions and the private sector – led the negotiations that culminated in the signing of three key FTAs that he said will be a powerful driving force behind Cambodian cassava exports to the signatory markets as well as the associated sector's attractiveness and marketability to investors. Ministry of Agriculture, Forestry and Fisheries data show that Cambodia exported 3.230 million tonnes of cassava and products thereof in January-November 2022, categorised as dried chips (1.817 million tonnes), fresh (1.332 million tonnes), starch (57,067 tonnes) and pulp (24,100 tonnes). The ministry lists Thailand, Vietnam, China, the US, Italy, the Netherlands, Canada, Malaysia, India and Singapore as formal buyers of Cambodian cassava and products thereof. *Source: Phnom Penh Post*

### Cambodia Says Trade in Services Important for Economic Growth

The trade in services is as important as trade in goods for economic growth, said H.E Sim Sokheng, Secretary of State of the Ministry of Commerce. While presiding over the national workshop on WTO Trade in Services: Key Features and Current Developments, His Excellency said that Trade in Services is just as critical as is Trade in Goods, when it comes to economic growth. If we look at the data, accordingly ASEAN statistics, services sector represents between 38% and 69% of ASEAN Member States' GDP. In the case of Cambodia, trade in services contributes more than 40% of our GDP. His Excellency pointed out that for the liberalization of trade in services, Cambodia signed up to ASEAN Framework Agreement on Services upon becoming ASEAN member in 1999. Following its accession to the WTO in 2004, Cambodia liberalized 94 sub-sectors across 11 main sectors, namely (1) Business services; (2) Communication Services; (3) Construction and Related Engineering Services; (4) Distribution Services; (5) Educational Services; (6) Environmental Services; (7) Financial Services; (8) Health Related and Social Services; (9) Tourism and Travel Related Services; (10) Recreational, Cultural and Sporting Services; and (10) Transport Services. *Source: Khmer Times*

## ស្រីលង្កាទទួលបានថវិកាសង្គ្រោះប្រមាណ ៣ពាន់លានដុល្លារពី IMF ដោយយកការកែទម្រង់ប្រឆាំងអំពើពុករលួយ ដែលមិនធ្លាប់មានពីមុនមក ជាថ្នូរ

មូលនិធិរូបិយវត្ថុអន្តរជាតិ IMF បានសម្រេចផ្តល់ថវិកាសង្គ្រោះប្រមាណ ៣ពាន់លានដុល្លារ សម្រាប់រយៈពេល៤ឆ្នាំ ដល់ស្រីលង្កាដើម្បីជួយស្តារសេដ្ឋកិច្ចប្រទេសនេះដែលកំពុងជាប់គាំងសាច់ប្រាក់ និងស្ថិតក្នុងស្ថានភាពដួលរលំសេដ្ឋកិច្ច ដែលមិនធ្លាប់បានឃើញក្នុងរយៈពេល ៧៥ឆ្នាំកន្លងមក បន្ទាប់ពីបំណុលរបស់ខ្លួនបានកើនឡើងដល់កំរិតដែលមិនអាចបង់ការប្រាក់លើប្រាក់កម្ចីបាន។ លោកស្រី Kristalina Georgieva នាយកគ្រប់គ្រង IMF បានលើកឡើងក្នុងសេចក្តីថ្លែងការណ៍មួយថា "ស្រីលង្កា បាននឹងកំពុងប្រឈមមុខនឹងបញ្ហាសេដ្ឋកិច្ចនិងសង្គមយ៉ាងខ្លាំង ជាមួយនឹងការធ្លាក់ចុះសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ចំពេលអតិផរណាខ្ពស់ ទុនបម្រុងធ្លាក់ចុះ បំណុលសាធារណៈគ្មាននិរន្តរភាព និងការកើនឡើងភាពងាយរងគ្រោះក្នុងវិស័យហិរញ្ញវត្ថុ"។ IMF បានលើកឡើងថា "កិច្ចខិតខំប្រឹងប្រែងបន្តដែលត្រូវធ្វើគឺដោះស្រាយអំពើពុករលួយ រួមទាំងការកែប្រែច្បាប់ប្រឆាំងអំពើពុករលួយផងដែរ"។ *ប្រភព៖ Independent*

## ក្រុមអ្នកវិនិយោគអារ៉ាប៊ីសាអូឌីត រងផលប៉ះពាល់ក្រោយការដួលរលំនៃធនាគារវិនិយោគ Credit Suisse

បញ្ហាប្រេងឡើងថ្លៃកាលពីឆ្នាំមុន បានធ្វើឱ្យការបណ្តាក់ទុនជាង ១,៥ប៊ីលានដុល្លាររបស់រាជទាយាទអារ៉ាប៊ីសាអូឌីត Mohammed bin Salman តាមរយៈធនាគារជាតិអារ៉ាប៊ីសាអូឌីតដែលគាំទ្រដោយរដ្ឋាភិបាលជាមួយធនាគារវិនិយោគ Credit Suisse បានធ្លាក់ចុះប្រមាណ -១,២៣%។ ការដួលរលំនៃធនាគារវិនិយោគ Credit Suisse ធ្វើឱ្យគម្រោងវិនិយោគតម្លៃរាប់ប៊ីលានដុល្លាររបស់មូលនិធិរដ្ឋនៃប្រទេសកាតា និងក្រុមគ្រួសារ Olayan មានមូលដ្ឋាននៅអារ៉ាប៊ីសាអូឌីត ត្រូវបានលុបចោល ជាហេតុនាំឱ្យតំបន់នៃឈូងសមុទ្រពែក្សក្លាយជាអ្នកខាតបង់ច្រើនជាងគេ ព្រោះតែការធ្លាក់ចុះភាគហ៊ុនហិរញ្ញវត្ថុ ចាប់តាំងពីការដួលរលំនៃធនាគារអាម៉េរិកធំៗចំនួនពីរ។ ការវិនិយោគរបស់អារ៉ាប៊ីសាអូឌីតនៅក្នុងធនាគារ Credit Suisse បង្កើតបាននូវច្រកចូលដ៏សំខាន់សម្រាប់ប្រទេសនេះ ទៅក្នុងវិស័យធនាគារពិភពលោក ដែលពង្រឹងភាពលេចធ្លោរបស់ខ្លួនជាមហាអំណាចវិនិយោគលើវិស័យប្រេង។ ការវិនិយោគរបស់អារ៉ាប៊ីសាអូឌីតបានជាប់គាំងនៅពេលប្រេងបានធ្លាក់ថ្លៃទាបជាង ១០០ដុល្លារក្នុងមួយបារ៉ែល ក្រោយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនបានប៉ះពាល់ដល់ទីផ្សារថាមពល។ *ប្រភព៖ The Wall Street Journal*

## ភាពច្របូកច្របល់របស់ធនាគារអាម៉េរិកនិងអឺរ៉ុប បានបង្កការភ័យខ្លាចជាសកល

ភាពចលាចលផ្នែកធនាគារអាម៉េរិក បន្ទាប់ពីការដួលរលំដំណាលគ្នានៃធនាគារ Silicon Valley និងធនាគារចំនួនពីរទៀតដែលផ្តោតលើបច្ចេកវិទ្យា និងអ្នកផ្តល់ប្រាក់កម្ចីដែលផ្តោតលើគ្រីបតូ គឺធនាគារ Signature Bank និង Silvergate Bank (SVB) ព្រោះតែការធ្លាក់ចុះនៃស្ថានភាពហិរញ្ញវត្ថុរបស់អាម៉េរិក និងបានបន្តរីករាលដាលដល់អឺរ៉ុបផងដែរ។ ការធ្លាក់ចុះនៃធនាគារ SVB និង Signature Bank បានបង្ហាញពីបរាជ័យលើវិស័យធនាគារដ៏ធំបំផុតទីពីរ និងទីបីនៅក្នុងប្រវត្តិសាស្ត្រអាម៉េរិក។ នៅអឺរ៉ុប ធនាគារ Credit Suisse ដ៏ធំរបស់ស្វីស ក៏កំពុងជួបបញ្ហាផងដែរ បន្ទាប់ពីត្រូវបានរកឃើញ "ភាពទន់ខ្សោយខាងសម្ភារៈ" នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន និងបន្ទាប់ពីម្ចាស់ភាគហ៊ុនធំជាងគេគឺធនាគារជាតិអារ៉ាប៊ីសាអូឌីត បាននិយាយថា ខ្លួននឹងមិនផ្តល់ជំនួយហិរញ្ញវត្ថុដល់ធនាគារនេះទៀតទេ។ *ប្រភព៖ Xinhua*

## រុស្ស៊ីឈរលើអារ៉ាប៊ីសាអូឌីត ជាអ្នកផ្គត់ផ្គង់ប្រេងកំពូលរបស់ចិន

រុស្ស៊ីបានវ៉ាដាច់អារ៉ាប៊ីសាអូឌីត ជាអ្នកផ្គត់ផ្គង់ប្រេងកំពូលរបស់ចិន ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ២០២៣ ដោយការនាំចូលប្រេងរបស់ចិនពីរុស្ស៊ីកើនឡើងជិតមួយភាគបួនធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២២។ វត្តមានប្រេងរបស់រុស្ស៊ីបានកើនឡើងដល់ ១៥,៦៨ លានតោនក្នុងរយៈពេលដូចគ្នានេះ ខណៈដែលការនាំចូលពីអារ៉ាប៊ីសាអូឌីតមានចំនួន ១៣,៩២លានតោន។ ការដាក់ទណ្ឌកម្មរបស់លោកខាងលិចនិងការកំណត់ថ្លៃលើប្រេងឆៅរុស្ស៊ីដែលជាប់សមុទ្រ បានធ្វើឱ្យរុស្ស៊ីធ្វើពាណិជ្ជកម្ម ដោយការលក់បញ្ចុះថ្លៃយ៉ាងច្រើនបើធៀបនឹងថ្លៃអន្តរជាតិ។ ការណ៍នេះផ្តល់អត្ថប្រយោជន៍ដល់ក្រុមហ៊ុនចម្រាញ់ប្រេងឯករាជ្យរបស់ប្រទេសចិន។ ទន្ទឹមនឹងនេះដែរ ការនាំចូលពីប្រទេសម៉ាឡេស៊ីបានកើនឡើង ១៤៤,២ភាគរយ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលជារឿយៗ ត្រូវបានប្រើប្រាស់ជាចំណុចអន្តរការីសម្រាប់ទំនិញ ដែលត្រូវបានទទួលទណ្ឌកម្មពីប្រទេសអ៊ីរ៉ង់ និងប្រទេសវេណេស៊ុយអេឡា។ *ប្រភព៖ ALJAZEERA*

## លោកស្រី Yellen ស្វែងរកការធានាឡើងវិញដល់សមាជិកសភាអាម៉េរិក បន្ទាប់ពីការដួលរលំធនាគារ

រដ្ឋមន្ត្រីក្រសួងរតនាគារអាម៉េរិក លោកស្រី Janet Yellen បានធានាដល់សមាជិកសភា និងពលរដ្ឋថា ប្រព័ន្ធធនាគាររបស់អាម៉េរិកគឺ "នៅតែល្អប្រសើរ" បន្ទាប់ពីការដួលរលំនៃធនាគារ Silicon Valley ដែលមានមូលដ្ឋាននៅរដ្ឋកាលីហ្វ័រញ៉ា ដែលជាការដួលរលំធនាគារធំបំផុតទីពីរនៅក្នុងប្រវត្តិសាស្ត្រអាម៉េរិក។ លោកស្រី Yellen ដែលប្រឈមមុខនឹងសវនាការគណៈកម្មាធិការហិរញ្ញវត្ថុព្រឹទ្ធសភាបាននិយាយថា ការសម្រេចចិត្តនេះ គឺជាផ្នែកមួយនៃសកម្មភាពជាបន្តបន្ទាប់ ដែលធ្វើឡើងដោយទីក្រុងវ៉ាស៊ីនតោន ដែលពួកគេរក្សាមិនបង្កើតជាការសង្គ្រោះ។ អ្នកដាក់ប្រាក់បញ្ញើ ដែលមានមូលនិធិមិនមានមានការធានារ៉ាប់រងលើសពី ២៥០.០០០ដុល្លារ ត្រូវបានធានានូវការការពារដោយការធានារ៉ាប់រងប្រាក់បញ្ញើសហព័ន្ធ។ វិធានការសង្គ្រោះបន្ទាន់ត្រូវបានដាក់ឱ្យដំណើរការ

ដើម្បីបង្កើនទំនុកចិត្តលើប្រព័ន្ធធនាគារ ប៉ុន្តែក្តីបារម្ភត្រូវបានលើកឡើងអំពីគំរូនៃការធានាប្រាក់បញ្ញើទាំងអស់។ *ប្រភព៖* [ALJAZEERA]

## ឥណ្ឌានិងសហភាពអឺរ៉ុប បញ្ចប់ការចរចាមួយជុំទៀតសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មដែលបានស្នើឡើង

ប្រទេសឥណ្ឌានិងសហភាពអឺរ៉ុប បានបញ្ចប់កិច្ចចរចាជុំទី៤ ស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីគ្រប់ជ្រុងជ្រោយ សំដៅពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចទ្វេភាគី។ ការចរចាបានបន្តពីឆ្នាំមុនបន្ទាប់ពីមានគម្លាតរយៈពេលប្រាំបីឆ្នាំ ប៉ុន្តែបានជាប់គាំងកាលពីមុនដោយសារតែការមិនចុះសម្រុងគ្នាលើបញ្ហារួមទាំងពន្ធគយលើរថយន្ត និងស្មារតី និងការចល័តរបស់ពលករជំនាញ។ កិច្ចចរចាជុំក្រោយគ្រោងធ្វើនៅថ្ងៃទី១២-១៦ ខែមិថុនា។ ការនាំចេញទំនិញរបស់ឥណ្ឌាទៅកាន់បណ្តាប្រទេសសហភាពអឺរ៉ុបមានចំនួនប្រហែល ៦៥ពាន់លានដុល្លារក្នុងឆ្នាំ ២០២១-២០២២ ជាមួយនឹងការនាំចូលចំនួន ៥១,៤ពាន់លានដុល្លារ។ ការចរចាក៏រួមបញ្ចូលទាំងកិច្ចព្រមព្រៀងលើការវិនិយោគ និងទំនិញសម្គាល់ភូមិសាស្ត្រ។ *ប្រភព៖* [The Economic Times]

## Sri Lanka Agrees $3bn IMF Bailout with Unprecedented Corruption Clause

The International Monetary Fund (IMF) has approved a nearly $3bn bailout programme for Sri Lanka over four years to help salvage the country's cash strapped economy, which was in a state of economic meltdown not seen in 75 years after its debt surged and the country was unable to pay interests on loans. "Sri Lanka has been facing tremendous economic and social challenges with a severe recession amid high inflation, depleted reserves, an unsustainable public debt, and heightened financial sector vulnerabilities," IMF managing director Kristalina Georgieva said in a statement. "The ongoing efforts to tackle corruption should continue, including revamping anti-corruption legislation," the IMF said. *Source: Independent*

## Credit Suisse Collapse Burns Saudi Investors

Riding an oil-price boom last year, Saudi Crown Prince Mohammed bin Salman directed government-backed Saudi National Bank to make a $1.5 billion investment in Credit Suisse CS -1.23%decrease. Credit Suisse's meltdown also erased billions of dollars in investments made by Qatar's sovereign fund and the Saudi-based Olayan family, making the Persian Gulf one of the biggest losers from a slide in financial stocks since the collapse of two U.S. banks. The Saudi investment in Credit Suisse was meant to be the kingdom's splashy entrance into the global banking sector, cementing its emerging status as an oil-fueled investing powerhouse. The Saudis struck the deal when oil prices were just below $100 a barrel, as Russia's invasion of Ukraine juiced energy markets. *Source: The Wall Street Journal*

## U.S., Europe in bank turbulence, triggering fears globally

The U.S. banking turmoil from the nearly simultaneous collapse of tech-focused Silicon Valley Bank, and two crypto-centric lenders Signature Bank and Silvergate Bank, continued to unfold this week, with the fallout penetrating deeper into the U.S. financial system and spreading to Europe. The downfall of SVB and Signature Bank marked the second-and third-largest bank failures in U.S. history. In Europe, Swiss banking giant Credit Suisse is also seeing issues after it revealed it found "Material weakness" in its financial reporting and after its largest shareholder, the Saudi National Bank, said it would not provide the bank with any more financial assistance. *Source: Xinhua*

## Russia overtakes Saudi Arabia as China's top oil supplier

Russia has surpassed Saudi Arabia as China's top oil supplier in the first two months of 2023, with Chinese imports of Russian oil rising by nearly one-quarter from the same period in 2022. Arrivals from Russia reached 15.68 million tonnes during the period, while imports from Saudi Arabia were at 13.92 million tonnes. Western sanctions and a price cap on seaborne Russian crude have led to it trading at deep discounts to international benchmarks, benefiting Chinese independent refiners. Meanwhile, imports from Malaysia rose 144.2 percent from the same period last year, often used as an intermediary point for sanctioned cargoes from Iran and Venezuela. *Source: ALJAZEERA*

## Yellen Seeks to Reassure US Legislators after Bank Collapse

US Treasury Secretary Janet Yellen has reassured lawmakers and citizens that the country's banking system is "sound" after the collapse of California-based Silicon Valley Bank, the second-largest bank collapse in US history. Yellen, who faced a Senate Finance Committee hearing, said the decision is part of a series of actions taken by Washington that they maintain do not constitute a bailout. Depositors with uninsured funds exceeding $250,000 have been assured of protection by federal deposit insurance. Emergency measures were launched to shore up confidence in the banking system, but concerns have been raised about the precedent of guaranteeing all deposits. *Source: ALJAZEERA*

## India, EU Conclude Another Round of Talks for Proposed Trade Agreement

India and the European Union (EU) have completed the fourth round of talks on a comprehensive free trade agreement aimed at strengthening economic ties between the two sides. Negotiations resumed last year after an eight-year gap, but had stalled previously due to disagreements on issues including customs duties on automobiles and spirits, and the movement of professionals. The next round of talks is scheduled for June 12-16. India's merchandise exports to EU countries were approximately $65bn in 2021-2022, with imports at $51.4bn. The negotiations also include agreements on investments and Geographical Indications (GI). *Source: The Economic Times*

## អនុសាសន៍សង្ខេប
## ស្តីពី
## ការពង្រឹងប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន៖ សិក្ខាសាលាតាមប្រព័ន្ធអនឡាញជាស៊េរី

### ១. សេចក្តីផ្តើម

មជ្ឈមណ្ឌល South Centre ហ្សឺណែវ, មជ្ឈមណ្ឌលសម្រាប់ការសិក្សារបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO), វិទ្យាស្ថានឥណ្ឌាសម្រាប់ពាណិជ្ជកម្មក្រៅប្រទេស ញូវដេលី, បណ្តាញតតីយលោកហ្សឺណែវ, សាលាអភិបាលកិច្ចសាធារណៈណែលសិន ម៉ានឌឺឡា, សាកលវិទ្យាល័យខេបថោនអាហ្វ្រិកខាងត្បូង, យុទ្ធសាស្រ្តគោលនយោបាយពាណិជ្ជកម្ម និងឧស្សាហកម្ម អាហ្វ្រិកខាងត្បូង, និងវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ កម្ពុជា បានរៀបចំសិក្ខាសាលាតាមប្រព័ន្ធអនឡាញជាស៊េរីចំនួន១០លើប្រធានបទរួមស្តីពី "ការពង្រឹងប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន" ក្នុងអំឡុងខែកញ្ញា ដល់ខែវិច្ឆិកា ឆ្នាំ ២០២០ ដែលមានវាគ្មិនជា រដ្ឋមន្រ្តីពាណិជ្ជកម្មបច្ចុប្បន្ននិងអតីត អតីតឯកអគ្គរាជ/រដ្ឋទូតប្រចាំអង្គការ WTO នៃប្រទេសកំពុងអភិវឌ្ឍន៍ មន្រ្តីរដ្ឋាភិបាល អ្នកសិក្សា អ្នកជំនាញពាណិជ្ជកម្ម និងតំណាងមកពីសង្គមស៊ីវិល។ បញ្ហាប្រឈមជាច្រើនដែលជះឥទ្ធិពលលើទិដ្ឋភាពផ្សេងៗនៃពាណិជ្ជកម្មអន្តរជាតិ ពាក់ព័ន្ធនឹងចំណុចសំខាន់អង្គការ WTO ត្រូវបានពិភាក្សានៅក្នុងវគ្គទាំងនេះ។ អនុសាសន៍សំខាន់ៗ និងដំណើរឆ្ពោះទៅមុខលើបញ្ហាផ្សេងៗ ដែលមានក្នុងវគ្គខាងលើ រួមជាមួយនឹងសាវតារពាក់ព័ន្ធ ត្រូវបានផ្តល់ជូនដូចខាងក្រោម៖

### ២. សាវតារ និងអនុសាសន៍សង្ខេប

#### ក. វិធីសាស្រ្តទូទៅ

អង្គការ WTO កំពុងជួបបញ្ហាខ្វែងគំនិតគ្នាលើដំណើរការរបស់ខ្លួន។ ប្រឈមនឹងការជាប់គាំង នៃការចរចាដ៏សំខាន់នៅក្រោមរបៀបវារៈ "អភិវឌ្ឍន៍" ទីក្រុងដូហា និងអសកម្មនៃអង្គឧទ្ធរណ៍ តម្រូវឱ្យមានការកែតម្រូវជាបន្ទាន់។ ការកើនឡើងនៃលទ្ធិឯកតោភាគីនិយមផ្នែកពាណិជ្ជកម្ម ជាពិសេសដោយសហរដ្ឋអាម៉េរិក និងអសមត្ថភាពរបស់អង្គការ WTO ក្នុងការបំពេញតួនាទីរបស់ខ្លួនឱ្យបានពេញលេញ បាននាំឱ្យមានគុណវិបត្តិ និងបញ្ហាប្រឈមជាមូលដ្ឋានមួយចំនួន ផងដែរ។ គួររំឭកផងដែរ បុព្វកថានៃកិច្ចព្រមព្រៀង Marrakesh ដើម្បីបង្កើតអង្គការ WTO បានទទួលស្គាល់ថា "ទំនាក់ទំនងរបស់សមាជិកក្នុងកិច្ចខិតខំប្រឹងប្រែងលើវិស័យពាណិជ្ជកម្មនិងសេដ្ឋកិច្ច គួរតែត្រូវបានអនុវត្តក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅ ធានាបាននូវការងារពេញលេញ និងកំណើនប្រាក់ចំណូលពិតច្រើននិងមានស្ថិរភាព និងតម្រូវការប្រកបដោយប្រសិទ្ធភាព ព្រមទាំងពង្រីកផលិតកម្ម និងពាណិជ្ជកម្ម លើផ្នែកទំនិញ និងសេវា"។ ដូច្នេះ ក្នុងរយៈពេល ២៥ ឆ្នាំ នៃការបង្កើតអង្គការ WTO វាជាការសំខាន់ដើម្បីពិនិត្យឡើងវិញ និងវាយតម្លៃថាតើ អង្គការ WTO សម្រេចបាននូវគោលដៅទាំងនេះ ឬក៏វិធានរបស់ខ្លួនជាផ្នែកមួយនៃការរារាំងប្រទេសកំពុងអភិវឌ្ឍន៍ ពីការសម្រេចបាននូវសក្តានុពលពេញលេញរបស់ពួកគេ។

ជាការពិត ប្រទេសអភិវឌ្ឍន៍តិចតួច ត្រូវការជំនួយចាំបាច់ ដើម្បីដោះស្រាយគុណវិបត្តិផ្នែកសេដ្ឋកិច្ច។ យុទ្ធសាស្រ្តរួមមួយសម្រាប់ដោះស្រាយបញ្ហាទាំងអស់ (one-size-fit-all strategy) ស្ទើរតែមិនមានប្រយោជន៍។ វិធីសាស្រ្តនេះ បានផ្តល់នូវប្រព្រឹត្តិកម្មពិសេសនិងដោយឡែកដែលមានការរឹតត្បិត ក្នុងទម្រង់បដិប្បញ្ញត្តិ ដែលមានរយៈពេលកំណត់ និងអន្តរកាលយូរជាងប្រទេសអភិវឌ្ឍន៍ រួមជាមួយជំនួយបច្ចេកទេស។ វិធីសាស្រ្តនេះ ក៏មិនទទួលបានជោគជ័យក្នុងការផ្តល់នូវលំហគោលនយោបាយចាំបាច់ ក្នុងការអភិវឌ្ឍរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ជាការពិត វិធានមួយចំនួនរបស់អង្គការ WTO មិនអាចសម្រេចបានតាមគោលបំណងដែលបានរំពឹងទុក។

លើសពីនេះ ប្រទេសមួយចំនួន ជាពិសេសប្រទេសអភិវឌ្ឍន៍ មានទស្សនៈថា មូលដ្ឋានគ្រឹះស្នូលពីររបស់អង្គការ WTO ដូចជា ការអនុវត្តតែមួយ និងការសម្រេចចិត្តដោយឯកច្ឆ័ន្ទ បានបង្ហាញឱ្យឃើញពីឧបសគ្គក្នុងការសម្រេចឱ្យបាននូវរបៀបវារៈ នៃកិច្ចប្រជុំទីក្រុងដូហា។ សំណើមួយចំនួន បានអំពាវនាវឱ្យអនុម័តយកវិធីសាស្រ្តដែលអាចបត់បែនបានចំពោះបញ្ហាទាំងពីរនេះ។

អង្គឧទ្ធរណ៍អសកម្ម បានរារាំងនូវសិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកក្នុងការអនុវត្តឱ្យបានត្រឹមត្រូវ ដោយទាញអង្គការ WTO ឱ្យទៅរកភាពដើមរបស់ខ្លួន (កិច្ចព្រមព្រៀងទូទៅស្តីពីទំនិញនិងពន្ធគយ) និងធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៍ធ្លាក់ក្នុងល្បែងភូមិសាស្រ្តនយោបាយ។ លើសពីនេះ ខណៈពេលដែល "ការកែទម្រង់របស់អង្គការ WTO" គឺជាប្រធានបទថ្មីចាប់តាំងពីឆ្នាំមុន ការធ្វើសំណើការកែទម្រង់ភាគច្រើន ហាក់ដូចជាមិនមានផលប្រយោជន៍ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍នោះទេ។ ដោយមិនអើពើនឹងការលំបាក ដែលប្រទេសកំពុងអភិវឌ្ឍន៍ប្រឈមមុខដោយពិចារណាអំពីឧបសគ្គគោលនយោបាយ ដែលដាក់ដោយអង្គការ WTO ហើយជំនួសមកវិញដោយជ្រើសរើសការផ្សព្វផ្សាយដទៃទៀតតម្រូវការសម្រាប់ការបញ្ចប់ឋានៈជាប្រទេសកំពុងអភិវឌ្ឍន៍ ការដាក់លក្ខខណ្ឌនៃការជូនដំណឹងដ៏តឹងរ៉ឹង និងការពង្រឹងលេខាធិការដ្ឋានអង្គការ WTO សំណើនេះចង្អុលយ៉ាងច្បាស់ឆ្ពោះទៅរកការកំណត់ វិស័យអាទិភាពមិនបានត្រឹមត្រូវ។ ដូច្នេះ វាមានសារសំខាន់ណាស់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការកំណត់អត្តសញ្ញាណមូលដ្ឋានរួមរបស់ពួកគេ និងបង្កើតរបៀបវារៈវិជ្ជមានរបស់ពួកគេនៅអង្គការ WTO ។

***<u>អនុសាសន៍</u>***

- ត្រូវការវិធីសាស្រ្តប្រកបដោយបរិយាប័ន្ន និងអភិវឌ្ឍន៍បន្ថែមទៀតចំពោះបញ្ហាប្រឈមធំៗនាពេល រាប់ចាប់ពីការប្រែប្រួល

អាកាសធាតុ ដល់ការទទួលយកបច្ចេកវិទ្យាឌីជីថល ហើយឥឡូវនេះ សង្វេបកម្មសេដ្ឋកិច្ចបណ្ដាលមកពីការបិទខ្ទប់អំឡុងជំងឺរាតត្បាតកូវីដ-១៩។

- ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវដាក់ចេញនូវចក្ខុវិស័យ ឬទម្រង់នៃពហុភាគីនិយម “ការកែទម្រង់សម្រាប់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន” ។ ការពង្រឹងពហុភាគីនិយមគឺជាតម្រូវការបន្ទាន់។
- សំណើប្រកបដោយនវានុវត្តន៍ ដូចជាគោលការណ៍ទីក្រុងហ្សឺណែវ របស់សន្និសីទអង្គការសហប្រជាជាតិសម្រាប់ពាណិជ្ជកម្ម និងអភិវឌ្ឍន៍ ស្ដីពី កិច្ចព្រមព្រៀងបៃតងសកលថ្មី គួរតែត្រូវបានអនុវត្តដោយប្រទេសកំពុងអភិវឌ្ឍន៍។ ការអភិវឌ្ឍដែលជំរុញវិធានពាណិជ្ជកម្មត្រូវតែអនុញ្ញាតឱ្យមានលំហគោលនយោបាយ ដើម្បីអនុវត្តគោលនយោបាយឧស្សាហកម្ម និងត្រូវបានធ្វើព្យាសកម្ម ដើម្បីអនុញ្ញាតឱ្យប្រទេសកំពុងអភិវឌ្ឍន៍ កសាងភាពខ្លាំងពាណិជ្ជកម្មថ្មី។ គោលការណ៍ទីក្រុងហ្សឺណែវ ចែងថា វិធានសកលគួរតែត្រូវបានធ្វើព្យាសកម្ម ឆ្ពោះទៅរកគោលដៅរួមនៃស្ថិរភាពសេដ្ឋកិច្ចសង្គម វិបុលភាពរួមគ្នា និងចីរភាពបរិស្ថាន។ លើសពីនេះ គោលការណ៍នេះក៏បញ្ជាក់ផងដែរថា ប្រជាជាតិនានាត្រូវដោះស្រាយបញ្ហារួមគ្នា ស្របតាមការទទួលខុសត្រូវរៀងៗខ្លួនក្នុងការបង្កើតប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដើម្បីលើកកម្ពស់និងការពារផលប្រយោជន៍រួមជាសកល។ គោលការណ៍ទាំងនេះក៏ទទួលស្គាល់នូវសិទ្ធិរបស់ប្រជាជាតិនានា ក្នុងលំហគោលនយោបាយ ដើម្បីបន្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។
- ការធ្វើសេចក្ដីសម្រេចដោយឯកច្ឆ័ន្ទ គឺជាលក្ខណៈពិសេសមួយរបស់អង្គការ WTO។ ការបោះបង់ចោលលក្ខណៈពិសេសនេះដោយជ្រើសរើសយកវិធីសាស្ត្រផ្សេង(Variable Geometry Model) នឹងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ហើយគួរតែត្រូវបានចៀសវាង។ ប្រទេសកំពុងអភិវឌ្ឍន៍ គួរតែប្រមូលផ្ដុំការគាំទ្ររបស់ពួកគេចំពោះការសម្រេចចិត្តជាឯកច្ឆ័ន្ទនេះ។

## ខ. ការកែទម្រង់អង្គការ WTO

ខណៈពេលដែលបញ្ហាកែទម្រង់អង្គការ WTO ត្រូវបានគិតគូជាបណ្ដើរៗ មានសំណើផ្លូវការតិចតួចប៉ុណ្ណោះដែលបានស្នើទៅអង្គការ WTO។ សំណើជាច្រើនស្ដីពីការកែទម្រង់ត្រូវបានធ្វើឡើងនៅខាងក្រៅអង្គការ WTO។ សំណើដែលដឹកនាំដោយប្រទេសអភិវឌ្ឍន៍អាចមានផលបច្ច័យយ៉ាងទូលំទូលាយចំពោះលំហគោលនយោបាយ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ជាឧទាហរណ៍ សហភាពអឺរ៉ុបបានរៀបចំឯកសារទស្សនទាន ស្ដីពីទំនើបភាវូបនីយកម្មរបស់អង្គការ WTO[1] (EU Concept Paper) ដែលមានសំណើបី៖ ទីមួយ ការធ្វើបច្ចុប្បន្នភាពសៀវភៅវិធានស្ដីពីពាណិជ្ជកម្មអន្តរជាតិ ដើម្បីឱ្យស្របតាមសេដ្ឋកិច្ចសកលនាពេលបច្ចុប្បន្ន។ ទីពីរ ការពង្រឹងតួនាទីតាមដានរបស់អង្គការ WTO; និងទីបី ការពុះពារភាពជាប់គាំងនៅក្នុងយន្តការដោះស្រាយវិវាទ របស់អង្គការ WTO។ ផ្នែកជាក់លាក់មួយចំនួនក្នុងសំណើរបស់ EU ត្រូវបានផ្ដល់ជូនខាងក្រោម៖

- ការបង្កើតវិធានដែលកម្រិតតួនាទី តាមរយៈការគ្រប់គ្រងការបង្ខូចទ្រង់ទ្រាយទីផ្សារ ដែលបង្កឡើងដោយសហគ្រាសគ្រប់គ្រងដោយរដ្ឋ (SOEs); ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើការឧបត្ថម្ភធន ដែលបង្ខូចទ្រង់ទ្រាយពាណិជ្ជកម្មច្រើនបំផុត ដូចជាការឧបត្ថម្ភធនដល់សហគ្រាស ដែលផលិតលើសតម្រូវការ; ការធានាគ្មានកំណត់ ការឧបត្ថម្ភធនដែលផ្ដល់ទៅឱ្យសហគ្រាសដែលជិតក្ស័យធនឬកំពុងមានវិបត្តិ ដោយគ្មានផែនការរៀបចំរចនាសម្ព័ន្ធឡើងវិញដែលអាចទុកចិត្តបាន ឬការកំណត់តម្លៃពីរផ្សេងគ្នា។
- ការបង្កើតវិធានថ្មីដើម្បីដោះស្រាយរបាំងវិនិយោគបរទេស និងការផ្ទេរបច្ចេកវិទ្យាដោយបង្ខំ និងបង្កើតសណ្ដាប់ធ្នាប់គ្របដណ្ដប់លើពាណិជ្ជកម្មឌីជីថល។
- សំណើសម្រាប់វិធីសាស្ត្រថ្មី ដើម្បីដោះស្រាយបញ្ហាអភិវឌ្ឍន៍៖ សមាជិកគួរតែត្រូវបានលើកទឹកចិត្តយ៉ាងសកម្មឱ្យ “ចាកចេញពី” ឬមិនចូលរួមក្នុងប្រព្រឹត្តិកម្មពិសេសនិងដាច់ដោយឡែក មិនថាការយល់ព្រមនៅកម្រិតដូចគ្នា ឬយល់ព្រមដោយកិច្ចព្រមព្រៀង។
- ពង្រឹងតួនាទីរបស់លេខាធិការដ្ឋានអង្គការ WTO។

ស្រដៀងគ្នានេះដែរ សេចក្ដីថ្លែងការណ៍រួមមួយត្រូវបានចេញផ្សាយបន្ទាប់ពីកិច្ចប្រជុំត្រីភាគី នៃរដ្ឋមន្ត្រីពាណិជ្ជកម្មអាម៉េរិក ជប៉ុន និងសហភាពអឺរ៉ុបដែលបានធ្វើឡើងកាលពីថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៨ នៅទីក្រុងញូវយ៉ក (គំនិតផ្ដួចផ្ដើមត្រីភាគី)[2] ដែលមានគោលបំណងចរចាវិធានថ្មីលើការឧបត្ថម្ភធនឧស្សាហកម្ម និងសហគ្រាសគ្រប់គ្រងដោយរដ្ឋ ដើម្បីដោះស្រាយការអនុវត្តការឧបត្ថម្ភធនដែលប៉ះពាល់ទីផ្សារ។ ប្រទេសកាណាដាក៏បានដាក់ឯកសារ[3] ជាផ្លូវការទៅអង្គការ WTO ដែលមានចំណងជើងថា “ការពង្រឹង និងធ្វើទំនើបកម្មអង្គការ WTO៖ ឯកសារពិភាក្សា”។ ឯកសារនេះសង្កត់ធ្ងន់ថាត្រូវតែចាត់វិធានការ ដើម្បីកែលម្អសេចក្ដីជូនដំណឹងរបស់សមាជិក។ សេចក្ដីជូនដំណឹងឆ្លើយតបពីសមាជិកផ្សេងទៀត និងការប្រមូលព័ត៌មានឯករាជ្យដោយលេខាធិការដ្ឋានអាច

[1] Concept Paper on WTO Modernisation, European Commission, 18 September 2018, Available at: https://trade.ec.europa.eu/doclib/docs/2018/september/tradoc_157331.pdf

[2] Available at https://ustr.gov/about-us/policy-offices/press-office/press-releases/2018/september/joint-statement-trilateral

[3] JOB/GC/201, dated 24 September 2018.

បំពេញចន្លោះប្រហោងដែលនៅសល់។ បន្ថែមលើនេះ ឯកសារនេះក៏ចែងថា វាជាការចាំបាច់ក្នុងការធ្វើទំនើបកម្មវិធានសម្រាប់សេដ្ឋកិច្ចទំនើប និងដោះស្រាយវិមាត្រសង្គម នៃសកលភាវូបនីយកម្ម ដូចជាពាណិជ្ជកម្មឌីជីថល ពាណិជ្ជកម្មប្រកបដោយបរិយាប័ន្ន ការអភិវឌ្ឍប្រកបដោយចីរភាព មីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យម ការវិនិយោគនិងបទប្បញ្ញត្តិក្នុងស្រុក។

ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះ ក៏បានដាក់សំណើមួយចំនួនពាក់ព័ន្ធនឹងការកែទម្រង់អង្គការពាណិជ្ជកម្មពិភពលោកផងដែរ។ សំណើមួយរបស់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះ[4] បានសង្កត់ធ្ងន់លើការប្រកាន់ខ្ជាប់នូវគោលការណ៍ជាមូលដ្ឋាននៃកិច្ចព្រមព្រៀង Marrakesh ដូចជាមុខងារពហុភាគីរបស់អង្គការពាណិជ្ជកម្មពិភពលោក ការសម្រេចចិត្តដោយឯកច្ឆ័ន្ទ ការដោះស្រាយបញ្ហាដោយពេញចិត្តក្រោមអាណត្តិដូហា ការការពារកង្វល់ពីការអភិវឌ្ឍ និងការដោះស្រាយបញ្ហាសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។ សំណើមួយទៀតបានគូសបញ្ជាក់ពីគម្លាតអភិវឌ្ឍន៍ និងបន្តពាក់ព័ន្ធនឹងប្រព្រឹត្តិកម្មពិសេស និងដោយឡែកសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ សេចក្តីថ្លែងការណ៍របស់ក្រុមប្រទេសអាហ្វ្រិក បានបង្ហាញពីបញ្ហាជាយូរអង្វែងដែលមានសារសំខាន់សម្រាប់អាហ្វ្រិក។ បញ្ហាទាំងនេះរួមមាន ការកាត់បន្ថយការគាំទ្រក្នុងស្រុកដែលបង្ខូចទីផ្សារក្នុងវិស័យកសិកម្ម ការកាត់បន្ថយឧបត្ថម្ភធនលើដំណាំកប្បាស យន្តការការពារពិសេស បញ្ហាប្រព្រឹត្តិកម្មពិសេសនិងដោយឡែក ការអនុវត្តនៃអាណត្តិដូហា និងគំនិតផ្តួចផ្តើមជំនួយពាណិជ្ជកម្ម។

ជាក់ស្តែង យោងតាមបទប្បញ្ញត្តិនៃប្រព្រឹត្តិកម្មពិសេសនិងដោយឡែក ក្នុងព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម GATT/WTO គេអាចកត់សម្គាល់បានថាបទបញ្ញត្តិទាំងនេះ មានសារសំខាន់សម្រាប់ការសម្រេចនូវគោលដៅមួយចំនួន នៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ បទប្បញ្ញត្តិនៃប្រព្រឹត្តិកម្មពិសេសនិងដោយឡែក អាចត្រូវបានបង្កើតឡើងដើម្បីជាផ្នែកមួយ នៃកិច្ចប្រឹងប្រែងជាវិជ្ជមានក្នុងការធានាថាប្រទេសកំពុងអភិវឌ្ឍន៍ដែលរួមទាំងប្រទេសអភិវឌ្ឍន៍តិចតួច ទទួលបាននូវចំណែក នៃកំណើនពាណិជ្ជកម្មអន្តរជាតិស្របតាមតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសទាំងនោះ។ ជារួម បទប្បញ្ញត្តិនៃប្រព្រឹត្តិកម្មពិសេសនិងដោយឡែក គឺជាការបង្ហាញនូវសកម្មភាពរួមគ្នាដោយភាគី នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម GATT និងសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបន្តការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍។ សមាជិកអង្គការពាណិជ្ជកម្មពិភពលោកមួយចំនួន ពិសេសសមាជិកដែលជាប្រទេសអភិវឌ្ឍន៍បានលើកឡើងថា ការចេញសេចក្តីថ្លែងការណ៍ដោយឯកឯងពីប្រទេសមួយចំនួនក្នុងការទទួលបានសិទ្ធិសម្រាប់ប្រព្រឹត្តិកម្មពិសេស និងដោយឡែក ប្រទេសនោះត្រូវទទួលខុសត្រូវសម្រាប់ការជាប់គាំងក្នុងកិច្ចប្រជុំដូហា។

***<u>អនុសាសន៍</u>***

(១) សំណើកែទម្រង់អង្គការពាណិជ្ជកម្មពិភពលោក *(WT/GC/W/778)*

- វាជាការចាំបាច់សម្រាប់សមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីតវ៉ាពីការកែទម្រង់ដែលមិនស្មើភាព ធ្វើឡើងដោយប្រទេសអភិវឌ្ឍន៍។ សំណើដែលលើកឡើងដោយប្រទេសអភិវឌ្ឍន៍អាចនឹងមិនសមស្រប ដែលប្រឆាំងនឹងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងប្រព័ន្ធផ្អែកលើមូលដ្ឋានច្បាប់ បង្កការខាតបង់ប្រយោជន៍ដល់ប្រទេសកំពុងប្រទេសអភិវឌ្ឍន៍លើប្រព្រឹត្តិកម្មពិសេសនិងដោយឡែក និងផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់អង្គការពាណិជ្ជកម្មពិភពលោកស្របតាមប្រទេសអភិវឌ្ឍន៍ទាំងនោះ។ ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវតែកំណត់ឡើងវិញនូវការកែទម្រង់អង្គការពាណិជ្ជកម្មពិភពលោក និងលើកកម្ពស់ការអភិវឌ្ឍពិតប្រាកដ និងការកែទម្រង់ប្រកបដោយបរិយាប័ន្ន។
- សំណើកែទម្រង់អង្គការពាណិជ្ជកម្មពិភពលោក របស់ប្រទេសកំពុងអភិវឌ្ឍន៍ (WT/GC/W/778) គួរតែត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីសង្កត់ធ្ងន់ពីសារសំខាន់នៃការដោះស្រាយបញ្ហាលើភាពមិនស្មើគ្នា ក្នុងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និងបញ្ហាជាយូរអង្វែង។ ប៉ុន្តែ ក៏គួរតែបង្កើតនូវទស្សនៈវិស័យថ្មីមួយ ជាពិសេសទាក់នឹងជំងឺរាតត្បាតកូវីដ១៩។ ដូចអ្វីដែលប្រទេសអភិវឌ្ឍន៍បានស្នើ សម្រាប់បង្កើតនូវលំហគោលនយោបាយសម្រាប់ពួកគេ។ ប្រទេសកំពុងអភិវឌ្ឍន៍ក៏គួរតែព្យាយាមស្នើនូវអ្វីដែលជួយដល់ការអភិវឌ្ឍជាចាំបាច់សម្រាប់ប្រជាជាតិរបស់ខ្លួន។

(២) ប្រកចូលទីផ្សារ៖ ការកំណត់ឡើងវិញនូវពន្ធ និងរបាំងមិនមែនពន្ធគយ

- ការអនុវត្តអត្រាពន្ធមូលដ្ឋានលើគ្រប់សមាជិកទាំងអស់ គឺជារឿងមួយដែលមិនត្រឹមតែមិនគោរពដល់ការចរចាកន្លងមក និងគិតគូរពីកម្រិតខុសគ្នា នៃការអភិវឌ្ឍក្នុងចំណោមសមាជិកទាំងអស់នោះទេ តែក៏ផ្ទុយពីគោលការណ៍បដិការមិនពេញលេញ (less-than-full-reciprocity) ដែលបានបញ្ចូលក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោកផងដែរ។
- របាំងមិនមែនពន្ធគយ បានបិទទីផ្សារសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងរយៈពេល២៥ ឆ្នាំចុងក្រោយនេះ អត្ថប្រយោជន៍ពីពន្ធ ដែលបានផ្តល់ឱ្យប្រទេសកំពុងអភិវឌ្ឍន៍មិនបានធ្វើឱ្យប្រសើរឡើងនូវប្រកចូលទីផ្សារនោះទេ។ ដូច្នេះ សំណើជាក់លាក់មួយពិតជាចាំបាច់ណាស់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។

[4] WT/GC/W/778.

(៣) ប្រព្រឹត្តិកម្មពិសេសនិងដោយឡែក

- ការប្តេជ្ញាចិត្ត ដោយផ្អែកលើគោលការណ៍បដិការពេញលេញ (full reciprocity) នឹងរារាំងសមត្ថភាពប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច។ ដូចនេះ ប្រព្រឹត្តិកម្មពិសេសនិងដោយឡែក គួរត្រូវបានរក្សា និងគាំទ្រការចរចាទាំងបច្ចុប្បន្ន និងអនាគតក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ នេះគឺជាសិទ្ធស្របច្បាប់របស់ប្រទេសកំពុងអភិវឌ្ឍន៍។ ដោយមិនគិតពីកម្រិតនៃការអភិវឌ្ឍន៍ កំហិតសមត្ថភាពនិងការអភិវឌ្ឍមិនស្មើភាព គឺជាលក្ខណៈរួមនៃសមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍។ ដូចនេះ ប្រទេសទាំងនេះត្រូវបានផ្តល់សិទ្ធិដើម្បីទទួលបានប្រយោជន៍ពីប្រព្រឹត្តកម្មពិសេស និងដោយឡែក ដែលផ្តល់ដោយច្បាប់អង្គការពាណិជ្ជកម្មពិភពលោក។
- ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវតែស្នើនូវរបៀបវារៈជាវិជ្ជមាន។ សំណើប្រព្រឹត្តិកម្មពិសេស និងដោយឡែកមួយរបស់ក្រុមប្រទេស G-៩០ បានបង្ហាញពីរបៀប ដែលប្រព្រឹត្តិកម្មពិសេសនិងដោយឡែកអាចត្រូវបានបង្កើតឡើងប្រកបដោយប្រសិទ្ធភាព និងអាចអនុវត្តបានស្របតាមមាត្រា៤៤ នៃសេចក្តីថ្លែងការណ៍ថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងដូហា។ សំណើទាំងនេះនឹងធ្វើឱ្យប្រសើរឡើងនូវសុខភាពសាធារណៈ លំហគោលនយោបាយដែលចាំបាច់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីពន្លឿនឧស្សាហូបនីយកម្ម បញ្ហាជញ្ជីងទូទាត់ (BOP) ជំនួយជាទឹកប្រាក់ក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម GATT និងការផ្ទេរបច្ចេកវិទ្យារួមទាំង សេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន និងការកម្រិតអំពីតួនាទី។
- សំណើនេះក៏គួរតែធ្វើឡើង ដើម្បីស្នើឱ្យប្រទេសអភិវឌ្ឍន៍បោះបង់នូវប្រព្រឹត្តិកម្មពិសេសនិងដោយឡែករបស់ខ្លួន។ កិច្ចព្រមព្រៀងលើវិស័យកសិកម្មមានសិទ្ធិពិសេសមួយចំនួនដែលផ្តល់ប្រយោជន៍ភាគច្រើនដល់ប្រទេសអភិវឌ្ឍន៍ទាំងនោះ។ ស្រដៀងគ្នានេះដែរ កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការតបត បានកំណត់នូវឥណទាននាំចេញមួយ ដែលត្រូវបានផ្តល់ឱ្យដោយអនុលោមតាមកិច្ចព្រមព្រៀងឥណទាននាំចេញរបស់ក្រុមប្រទេស OECD ដែលមិនត្រូវបានចាត់ទុកជាការឧបត្ថម្ភធនហាមឃាត់។ កិច្ចពិភាក្សាណាមួយស្តីពីប្រព្រឹត្តិកម្មពិសេសនិងដោយឡែក តម្រូវឱ្យប្រទេសអភិវឌ្ឍន៍បោះបង់នូវសិទ្ធិពិសេសនេះ។

(៤) តម្លាភាព

- ដំណើរឆ្ពោះទៅមុខទៅរកអនុលោមតាមកាតព្វកិច្ចតម្លាភាព គឺជារឿងទីមួយ ហើយការស្វែងយល់ពីមូលហេតុនៃការអនុលោមមិនបានល្អ ឬមិនអនុលោម និងរបៀបដែលអង្គការពាណិជ្ជកម្មពិភពលោកជួយដោះស្រាយនូវបញ្ហានេះគឺជារឿងទីពីរ។ ត្រឹមតែស្នើឱ្យប្រទេសកំពុងអភិវឌ្ឍន៍ ស្វែងរកជំនួយពីអង្គការពាណិជ្ជកម្មពិភពលោកគឺមិនគ្រប់គ្រាន់នោះទេ ខណៈមានបញ្ហាផ្ទៃក្នុងជាច្រើនដូចជា រដ្ឋបាលមានកម្រិតតូច ការផ្លាស់ប្តូរបុគ្គលិកជាញឹកញាប់ និងបញ្ហាដទៃទៀត។ ការមានវិធីសាស្ត្ររួមគ្នាមួយគឺជារឿងចាំបាច់ ដើម្បីយល់ពីបញ្ហាជាមូលដ្ឋាននៃប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះ និងធានានូវតម្លាភាព។
- កត្តាតម្លាភាពមិនគួរកំណត់ត្រឹមតែជាការជូនដំណឹងនោះទេ គួរតែអនុវត្តលើគ្រប់ដំណើរការទាំងអស់ របស់អង្គការពាណិជ្ជកម្មពិភពលោក រួមទាំងការធ្វើសេចក្តីសម្រេចចិត្តអំឡុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងដំណើរការមុនកិច្ចប្រជុំនៅហ្សឺណែវ។

(៥) ការប្រព្រឹត្តិទៅរបស់អង្គការពាណិជ្ជកម្មពិភពលោក

- គំនិតផ្តួចផ្តើមធ្វើឱ្យប្រសើរឡើងនូវការប្រព្រឹត្តិទៅ របស់អង្គការ WTO មិនគួរធ្វើឱ្យការចូលរួមរបស់ប្រទេសកំពុងអភិវឌ្ឍន៍មានការពិបាកដោយអចេតនាទេ ។
- អព្យាក្រឹតភាពនៃលេខាធិការដ្ឋានរបស់អង្គការ WTO មិនគួរត្រូវបានប៉ះពាល់នោះទេ។ លើសពីនេះទៀត ការិយាធិបតេយ្យមានស្មុគស្មាញរួចទៅហើយ ដែលមិនគួរត្រូវបានបង្កើតបន្ថែមទៀតពីលើអ្វីដែលមានស្រាប់ទេ។

(៦) ស្ថានភាពលក្ខខណ្ឌទីផ្សារ និងការឧបត្ថម្ភធនឧស្សាហកម្ម

- តម្រូវការភ្លាមៗ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍មិនមែនត្រឹមតែជាជំហរការពារទប់ទល់ទេ ប៉ុន្តែជាជំហរទាមទារឱ្យបាននូវការឧបត្ថម្ភធនដល់វិស័យឧស្សាហកម្ម ជាពិសេសអំឡុងពេលដែលមានជំងឺរាតត្បាត ។
- វិធាននៃការឧបត្ថម្ភធន ដែលមានស្រាប់របស់អង្គការ WTO គឺបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់លំហគោលនយោបាយ សម្រាប់ការអភិវឌ្ឍប្រទេសកំពុងអភិវឌ្ឍន៍ ដូចនេះប្រទេសកំពុងអភិវឌ្ឍន៍គួរតែអំពាវនាវ ឱ្យមានការបន្ធូរបន្ថយវិធានការប្រឆាំងឧបត្ថម្ភធន និងវិធានការតបត មិនមែនការរឹតបន្តឹងវិធានការប្រឆាំងឧបត្ថម្ភធន និងវិធានការតបត ថែមទៀតនោះទេ។ របៀបវារៈនៃការកែទម្រង់អង្គការ WTO គួរតែបង្កើតឡើងដោយប្រទេសកំពុងអភិវឌ្ឍន៍ និងគួរតែបញ្ចូលនូវការបន្ធូរបន្ថយវិធានការប្រឆាំងឧបត្ថម្ភធន និងវិធានការតបត ដោយផ្តោតលើប្រព្រឹត្តិកម្មពិសេស និងដោយឡែក។ វាជារឿងសំខាន់ណាស់ ពីព្រោះប្រទេសកំពុងអភិវឌ្ឍន៍មិនមានធនធានហិរញ្ញវត្ថុ ឬក៏ការលើកលែងសារពើពន្ធគ្រប់គ្រាន់ ដើម្បីផ្តល់ការឧបត្ថម្ភធនដូចអ្វីដែលប្រទេសអភិឌ្ឍន៍ កំពុងបានឧបត្ថម្ភធនដល់ក្រុមហ៊ុនបច្ចេកវិទ្យាធំៗរបស់ខ្លួននោះទេ។ ក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថលនេះ ក្រុមហ៊ុនបច្ចេកវិទ្យាធំៗ បានទទួលនូវអត្ថប្រយោជន៍មួយជំហានមុនរួចទៅហើយ ដែលនាំឱ្យមានការរីកចម្រើនផ្នែកឌីជីថល។

### គ. វិបត្តិអង្គឧទ្ធរណ៍

បញ្ហាចម្បងមួយ ដែលអង្គការ WTO កំពុងប្រឈមគឺការដួលរលំនៃអង្គឧទ្ធរណ៍។ ករណីនេះ ក៏ជាផ្នែកមួយស្ថិតក្នុងសំណើនៃការកែទម្រង់របស់អង្គការ WTO ផងដែរ សំណើខ្លះត្រូវបានស្នើឡើងឱ្យមានការផ្លាស់ប្តូរស្ថាប័ននេះ។ ខណៈសំណើរបស់សហភាពអឺរ៉ុបស្តីពីការរៀបចំមជ្ឈត្តកម្មឧទ្ធរណ៍ពហុភាគីបណ្តោះអាសន្ន(MPIA) ដែលផ្តល់នូវការរៀបចំស្ថាប័នបណ្តោះអាសន្នសម្រាប់វិបត្តិអង្គឧទ្ធរណ៍ ហើយក៏មានសំណើផ្សេងទៀតដូចជា តួនាទីរបស់លេខាធិការដ្ឋាន ការអនុវត្តតែមួយដូចគ្នា (single undertaking) និងប្រធានបទជាច្រើនទៀត។ សំណើទាំងនេះគួរតែត្រូវបានពិភាក្សាយ៉ាងលម្អិត។

សំណើស្តីពី ការរៀបចំមជ្ឈត្តកម្មឧទ្ធរណ៍ពហុភាគីបណ្តោះអាសន្នរបស់សហភាពអឺរ៉ុបនេះ ដែលអនុលោមតាមមាត្រា ២៥ នៃការយល់ដឹងអំពីវិធាន និងនីតិវិធីគ្រប់គ្រងការដោះស្រាយវិវាទ គឺដើម្បីផ្តល់សិទ្ធិក្នុងការដោះស្រាយបណ្តោះអាសន្ន រហូតដល់ការបញ្ចប់ការជាប់គាំងក្នុងការតែងតាំងសមាជិកអង្គឧទ្ធរណ៍។ យោងតាមតាមអណត្តិរបស់មជ្ឈត្តកម្មឧទ្ធរណ៍ពហុភាគីបណ្តោះអាសន្ន (MPIA) ភាគីនឹងចុះកិច្ចព្រមព្រៀងមជ្ឈត្តកម្មបណ្តឹងឧទ្ធរណ៍ សម្រាប់ដោះស្រាយជម្លោះរៀងៗខ្លួន ហើយអង្គជំនុំជម្រះក្តីនឹងត្រូវព្យួរក្រោមមាត្រា ១២.១២ នៃអង្គភាពដោះស្រាយវិវាទ មុនពេលប្រកាសសាលក្រមចុងក្រោយ។ អង្គឧទ្ធរណ៍នេះទាមទារឱ្យអនុវត្តន៍ និងនីតិវិធីនៃមាត្រា ១៧ នៃអង្គភាពដោះស្រាយវិវាទឱ្យដូចនឹងអង្គឧទ្ធរណ៍អចិន្ត្រៃយ៍តាមតែអាចធ្វើបាន។ គិតត្រឹមខែធ្នូ ឆ្នាំ២០២០ សមាជិក WTO ២៤ប្រទេស បានគាំទ្រចំពោះសំណើ និងនៅតែបើកចំហសម្រាប់ទទួលសមាជិកភាពជទៃផ្សេងទៀត។ ទោះជាយ៉ាងណា មន្ទិលសង្ស័យពាក់ព័ន្ធនឹងការថយចុះនៃតួនាទី នៃអង្គភាពដោះស្រាយវិវាទ (DSB) នៅក្នុងដំណើរការដោះស្រាយវិវាទនៅតែមាន ការផ្តល់ថវិកានិងការគាំទ្រពីលេខាធិការដ្ឋាន និងស្ថានភាពនៃមជ្ឈត្តកម្មឧទ្ធរណ៍ដែលមិនបានអនុម័ត និងរបាយការណ៍នៃអង្គជំនុំជម្រះក្តីដែលត្រូវបានព្យួរ និងការអនុលោមតាមច្បាប់របស់ពួកគេ។

***អនុសាសន៍***

- សមាជិក គួរតែជានាការរក្សាប្រព័ន្ធដោះស្រាយវិវាទពីរថ្នាក់ (two-tier) នៃយន្តការដោះស្រាយវិវាទរបស់អង្គការ WTO ដោយជំនួសយន្តការអង្គជំនុំជម្រះឧទ្ធរណ៍ ដែលមាននាពេលបច្ចុប្បន្ន ជាមួយនឹងយន្តការដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម GATT នឹងធ្វើឱ្យខូចដល់វឌ្ឍនភាព ដែលធ្វើឡើងដោយប្រទេសនានាក្នុងអំឡុងពេលចរចាកិច្ចប្រជុំអ៊ុយរ៉ាហ្គាយ។
- សមាជិកប្រទេសកំពុងអភិវឌ្ឍន៍ គួរតែបន្តកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេសម្រាប់ការរស់ឡើងវិញ នៃស្ថាប័នបណ្តឹងឧទ្ធរណ៍។ យន្តការមជ្ឈត្តកម្មឧទ្ធរណ៍បណ្តោះអាសន្នពហុភាគី (MPIA) មានចំណុចខ្វះខាតជាច្រើន និងកាត់បន្ថយការគ្រប់គ្រងសមាជិកលើដំណើរការដោះស្រាយវិវាទ។ ដូច្នេះហើយ វាមិនមែនជាដំណោះស្រាយរយៈពេលវែង ដែលអាចទុកចិត្តបានសម្រាប់វិបត្តិបច្ចុប្បន្ននោះទេ។

### ឃ. ការឧបត្ថម្ភធនលើវិស័យជលផល

ការចរចាលើការឧបត្ថម្ភធនលើវិស័យជលផល នាពេលបច្ចុប្បន្នកំពុងដំណើរការនៅអង្គការ WTO។ ជាមួយនឹងធាតុសំខាន់ៗមួយចំនួនរួមទាំងប្រព្រឹត្តិកម្មពិសេសនិងដោយឡែក ដែលនៅតែស្ថិតក្រោមការពិចារណា។ វាមានសារសំខាន់ក្នុងការធានាថាលទ្ធផលចុងក្រោយប្រកបដោយគុណភាព ។

***អនុសាសន៍***

- តម្រូវឱ្យមានការចរចា ដើម្បីដោះស្រាយបញ្ហាដែលជាប់ទាក់ទងនឹងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជានេសាទ ជាពិសេសការនេសាទខ្នាតតូច។
- តម្រូវឱ្យមានការចរចារ អំពីវិធានប្រកបដោយប្រសិទ្ធភាពសម្រាប់របៀបនៃការឧបត្ថម្ភធន ដែលត្រូវបានផ្តល់សម្រាប់ឧស្សាហកម្មនេសាទ។
- ចាំបាច់ត្រូវរក្សាលំហគោលនយោបាយ ដើម្បីអភិវឌ្ឍសមត្ថភាពនាពេលអនាគត។

### ង. វិស័យកសិកម្ម

គោលបំណងរួម នៃការចរចាលើវិស័យកសិកម្មក្នុងអំឡុងពេលកិច្ចប្រជុំអ៊ុយរ៉ាហ្គាយ គឺផ្តោះទៅរកប្រព័ន្ធពាណិជ្ជកម្មដែលផ្តោតលើប្រព័ន្ធទីផ្សារស្មើភាពលើវិស័យកសិកម្ម។ ខណៈពេលនេះ កិច្ចព្រមព្រៀងស្តីពីកសិកម្មត្រូវបានទទួលស្គាល់ថាបានទទួលបរាជ័យ ព្រោះតែភាពមិនស៊ីមេទ្រី និងអតុល្យភាពជាច្រើន ដែលបាននិងកំពុងធ្វើឱ្យខូចប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនទៀត។ អតុល្យភាពទាំងនេះប៉ះពាល់ដល់សសរស្តម្ភទាំងបី - ប្រកចូលទីផ្សារ ការគាំទ្រក្នុងស្រុក និងការប្រកួតប្រជែងលើការនាំចេញ។ កត្តាគំរាមកំហែងរួមដែលពាក់ព័ន្ធគឺ៖ ប្រទេសទាំងឡាយណាដែលបង្ខូចទ្រង់ទ្រាយទីផ្សារតាមរយៈការដាក់អត្រាពន្ធគយខ្ពស់ ភាពសម្បូរបែបនៃរបាំងមិនមែនពន្ធគយ និងការឧបត្ថម្ភធនខ្ពស់ ការធានាបាននូវសិទ្ធិក្នុងការបង្ខូចទីផ្សារតាមរយៈការដាក់ពន្ធ និងការឧបត្ថម្ភធន។ ម្យ៉ាងវិញទៀត ប្រទេសដែលមិនដាក់របាំងមិនមែនពន្ធ ឬដាក់របាំងពន្ធតិចតួច និងការផ្តល់នូវការឧបត្ថម្ភធនទាប បានបាត់បង់សិទ្ធិការពារវិស័យកសិកម្មរបស់ពួកគេ។

***អនុសាសន៍***

- ភាពមិនស៊ីចង្វាក់គ្នា និងអតុល្យភាពនៅក្នុងពាណិជ្ជកម្មកសិកម្មគួរតែត្រូវបានដោះស្រាយ ហើយការលុបបំបាត់នៃវិធានការរួមនៃការគាំទ្រការបង្ខូចទ្រង់ទ្រាយពាណិជ្ជកម្ម គួរតែជាអាទិភាព

ចម្បង។ នេះក៏នឹងជួយដោះស្រាយការប្រែប្រួលអាកាសធាតុផងដែរ។

- ប្រទេសកំពុងអភិវឌ្ឍន៍ គួរតែផ្តល់អទិភាពលើការគាំទ្រក្នុងស្រុកជាមុន រួមមាន៖ កប្បាស ការកាន់កាប់សន្និធិ សម្រាប់សន្តិសុខស្បៀងសាធារណៈ និងយន្តការការពារពិសេស។
- ការចរចាគួរតែផ្តោតសំខាន់លើយន្តការការពារពិសេស ព្រមទាំងសាមញ្ញកម្មពន្ធគយ ពន្ធគយខ្ពស់ចំពោះទំនិញរសើប (Tariff Peak) និងការដំឡើងពន្ធចំពោះផលិតផលពាក់កណ្តាលសម្រេច និងសម្រេចច្រើនជាងវត្ថុធាតុដើម ដើម្បីការពារឧស្សាហកម្មផលិតក្នុងស្រុករបស់ពួកគេ (tariff escalations) ។
- កប្បាស អាចជាទំនិញសម្រាប់ដាក់បញ្ចូលនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីទី១២ ដើម្បីធ្វើការចរចាសម្រេចឱ្យបាន ។
- គោលបំណង នៃដំណោះស្រាយអចិន្ត្រៃយ៍ចំពោះការកាន់កាប់សន្និធិសម្រាប់សន្តិសុខស្បៀងសាធារណៈ នឹងត្រូវធ្វើការចរចាសម្រេចជាបន្ទាន់។
- ឥណទាននាំចេញមានផលប៉ះពាល់យ៉ាងខ្លាំង ហើយចាំបាច់ត្រូវតែធ្វើឱ្យមានរបៀបរៀបរយ។ ឥណទាននាំចេញនៅក្នុងកំណែទម្រង់សេចក្តីព្រាង សម្រាប់ទំនិញកសិកម្ម (TN/AG/W/4/Rev.4) ដែលត្រូវតាមដាន និងអនុវត្តបានលឿន ដូចជាការឧបត្ថម្ភធននាំចេញ ដែលត្រូវបានជ្រើសរើសដើម្បីអនុវត្ត ។
- របៀបរៀបរយជំនួយស្បៀងក៏ត្រូវយល់ព្រមផងដែរ លើការប្រើប្រាស់ទម្រង់បែបបទសេចក្តីព្រាង ដែលបានកែសម្រួលសម្រាប់កសិកម្ម (TN/AG/W/4/Rev.4) ដោយផ្អែកលើមូលដ្ឋានសម្រាប់ការចរចាបន្ថែម។
- ទិន្នន័យ ដែលត្រូវបំពេញសម្រាប់កូតាអត្រាពន្ធគឺទាបណាស់នៅក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួន ហើយចាំបាច់ត្រូវមានការដោះស្រាយ។ នេះគឺដោយសារប្រព័ន្ធអាជ្ញាប័ណ្ណមិនមានតម្លាភាពដែលត្រូវបានប្រើ ដើម្បីទប់ស្កាត់ការនាំចូល ។
- តម្រូវការនៃការពិភាក្សាអំពីវិធានការអនាម័យ និងភូតគាមអនាម័យ ត្រូវបានប្រើប្រាស់ខុសសម្រាប់ជារបាំងមិនមែនពន្ធ ហើយត្រូវបញ្ចូលបញ្ហានេះទៅក្នុងរបៀបវារៈនៃការចរចានាពេលអនាគត។

## ច. គំនិតផ្តួចផ្តើមសេចក្តីថ្លែងការណ៍រួម

សមាជិកអង្គការ WTO មួយចំនួនបានចាប់ផ្តើមគំនិតផ្តួចផ្តើមសេចក្តីថ្លែងការណ៍រួម (JSI) ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក កិច្ចសម្រួលការវិនិយោគ បទប្បញ្ញត្តិសេវាកម្មក្នុងស្រុក ។ល។ ទាំងនេះមិនមានអាណត្តិសមាជិកភាពផ្លូវការរបស់អង្គការ WTO ទេ ហើយមានការព្រួយបារម្ភអំពីរបៀបនៃការបង្កើតច្បាប់ ដែលមានសក្តានុពលនៅក្នុងគំនិតផ្តួចផ្តើមទាំងនេះនឹងអន្តរកម្មជាមួយក្របខ័ណ្ឌច្បាប់ដែលមានស្រាប់។

***<u>អនុសាសន៍</u>***

- គំនិតផ្តួចផ្តើមសេចក្តីថ្លែងការណ៍រួមកំពុងបង្កើតវិធានថ្មី ដែលមិនត្រូវបានពិភាក្សានៅអង្គការ WTO និងការពិភាក្សាអំពីវិធានស្របទៅនឹងរបៀបវារៈកិច្ចព្រមព្រៀងពហុភាគី។ មានការលុបចោលការពិភាក្សាចេញពីដំណើរការបើកចំហ តម្លាភាព និងដំណើរការប្រកបដោយបរិយាប័ន្ន ហើយលទ្ធផលអាចត្រូវបាននាំយកទៅអនុវត្តនៅក្នុងអង្គការ WTO នៅពេលក្រោយ។ គំនិតផ្តួចផ្តើមសេចក្តីថ្លែងការណ៍រួមកំពុងធ្វើឱ្យមានការបែកបាក់ នៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ ដូច្នេះ រាល់ការសម្រេចជាផ្លូវការនៃលទ្ធផល អាចត្រូវបានធ្វើឡើងដោយអនុលោមទៅតាមវិធានរបស់អង្គការ WTO ដែលមានស្រាប់តាមការកែប្រែ និងការសម្រេចចិត្តដោយឯកច្ឆន្ទ។

## ឆ. លទ្ធភាពទទួលបានឱសថដែលមានតម្លៃសមរម្យ

ទិដ្ឋភាពទូទៅទាក់ទងនឹងពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញារបស់អង្គការ WTO (កិច្ចព្រមព្រៀង TRIPS) មានសារសំខាន់ក្នុងការធ្វើឱ្យចុះសម្រុងគ្នានៃការការពារកម្មសិទ្ធិបញ្ញាឆ្លងដែន និងពង្រីកសិទ្ធិផ្តាច់មុខចំពោះប្រកាសនីយបត្រតក្កកម្ម ក្នុងចំណោមផលិតផលផ្សេងទៀត។ ចាប់តាំងពីពេលនោះមក របបកម្មសិទ្ធិបញ្ញា ជាពិសេសប្រកាសនីយបត្រតក្កកម្ម បានក្លាយជាឧបករណ៍យុទ្ធសាស្ត្រដ៏សំខាន់មួយដែលកាន់កាប់ដោយក្រុមហ៊ុនថ្នាំពេទ្យធំៗ និងក្រុមហ៊ុនមេរបស់ពួកគេដែលរកបានប្រាក់ចំណេញដ៏ច្រើន តាមរយៈការចំណាយរបស់មនុស្សរាប់ពាន់លាននាក់បានស្លាប់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច។[5] ភាពបត់បែនដែលបានដាក់បញ្ចូលក្នុងកិច្ចព្រមព្រៀង TRIPS ដូចជាការផ្តល់អាជ្ញាប័ណ្ណកាតព្វកិច្ច ការនាំចូលស្របគ្នា ការលើកលែងការស្រាវជ្រាវ និងការលើកលែងផ្សេងទៀតបានបង្ហាញថាមានប្រសិទ្ធភាពតិចតួចក្នុងការជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច។ លើសពីនេះ ការកើនឡើងនៃបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង TRIPS-plus នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងតំបន់នាពេលថ្មីៗនេះ បានកាត់បន្ថយលំហគោលនយោបាយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច។ បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង TRIPS-plus មានផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ទៅលើលទ្ធភាពទទួលបានឱសថសំខាន់ៗ។ បទប្បញ្ញត្តិដែលតម្រូវឱ្យពន្យារ/ការកែសម្រួលរយៈពេលប្រកាសនីយបត្រតក្កកម្ម ភាពផ្តាច់មុខនៃទិន្នន័យ តំណភ្ជាប់ប្រកាសនីយបត្រតក្កកម្ម បានចាប់ផ្តើមលេចឡើងម្តងហើយ

[5] Ellen F.M. 'T Hoen, 'TRIPS Pharmaceutical Patents and Access to Essential Medicines: Seattle, Doha and Beyond' 3 (1) *Chicago Journal of International Law* (2002).

ម្តងទៀតនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតំបន់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (RTAs/FTAs) ជាហេតុផ្តល់កម្លាំងរុញច្រានដល់ក្រុមហ៊ុនឱសថធំក្នុងការពង្រីករយៈពេល និងវិសាលភាពនៃប្រកាសនីយបត្រតក្កកម្មរបស់ពួកគេ។

